# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...៧៤...សសរ**

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការប្រវត្តិសាស្ត្រ សម្រាប់និពន្ធរឿងអធិរាជាណាចក្រខ្មែរ និងក្រុងអង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១:** បង្កើតគណៈកម្មាធិការប្រវត្តិសាស្ត្រ សម្រាប់និពន្ធរឿងអធិរាជាណាចក្រខ្មែរ និងក្រុងអង្គរ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២- | ឯកឧត្តម **នុត ណារ៉ាង** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣- | ឯកឧត្តម **ឈន អៀម** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ៤- | ឯកឧត្តម **ជុច តឿន** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៥- | ឯកឧត្តម **មិន ឃិន** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ៦- | ឯកឧត្តម **រស់ រ៉េន** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ៧- ឯកឧត្តម នី យ៉ាច | អនុប្រធាន ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | សមាជិក |
| ៨- ឯកឧត្តម ស៊ន សំណាង | ប្រធាន រាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| ៩- ឯកឧត្តម ទី តាយី | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- ឯកឧត្តម សោម សុគន្ធ | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១- លោកជំទាវ តាន់ ធានី | អគ្គលេខាធិការ គណៈកម្មការជាតិសម្រាប់យូណេស្កូ | សមាជិក |
| ១២- ឯកឧត្តម ពេជ កែច | សមាជិក ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | សមាជិក |
| ១៣- ឯកឧត្តម អ៊ុក សារមេត្ត | អគ្គនាយករង អាជ្ញាធរអប្សរា | សមាជិក |
| ១៤- ឯកឧត្តម រស់ បូរ៉ាត់ | អគ្គនាយករង អាជ្ញាធរអប្សរា | សមាជិក |
| ១៥- ឯកឧត្តម ហ៊ុន សុត | អគ្គនាយក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៦- ឯកឧត្តម អ៊ុច ចំន | អនុប្រធាន រាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| ១៧- ឯកឧត្តម ឡុង សៀម | ប្រធាន វិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១៨- ឯកឧត្តម សួស យ៉ារ៉ា | អគ្គលេខាធិការរង អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិកប្រចាំការ |
| ១៩- បណ្ឌិត មុខ សុចត្តិ | អគ្គនាយករង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២០- លោក គង់ កន្ធារា | ប្រធាន នាយកដ្ឋានភាពយន្ត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២១- លោក ចាប់ ឡុច | អនុប្រធាន នាយកដ្ឋានសារមន្ទីរ | សមាជិក |
| ២២- លោក សួន សុចណ្ណា | មន្ត្រី ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៣- លោក ចេក ចន | សាស្ត្រាចារ្យ សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | សមាជិក |
| ២៤- លោក សេង សំអាន | មន្ត្រី នាយកដ្ឋានសិល្បៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៥- លោក នុង សេដ្ឋា | មន្ត្រី អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| ២៦- លោក លី ចំនួមុនី | មន្ត្រី អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| ២៧- លោកស្រី ខន អណ្ណែត | មន្ត្រី អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| ២៨- លោក ម្ប្រាស់ លឹម | មន្ត្រី អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| ២៩- លោក សោម ជាតិ | មន្ត្រី អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |

**ប្រការ ២ :** គណៈកម្មាធិការនេះ មានភារកិច្ចដូចតទៅ :

- ស្រាវជ្រាវប្រវត្តិសាស្ត្រ សិលាចារិក និងឯកសារពាក់ព័ន្ធ អំពីការកកើតទឹកដីកម្ពុជា និងកំណើតក្រុងអង្គរ
- និពន្ធខ្លឹមសាររឿងសម្រាប់ថតខ្សែភាពយន្តអេឡិចត្រូនិច (3 Dimension)
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងភាគីមិត្ត (សាធារណរដ្ឋកូរ៉េ) ដើម្បីសម្រេចលទ្ធផលជាវិជ្ជមាន ចំពោះខ្សែភាពយន្តកម្រិតជាតិ សម្រាប់ផ្សព្វផ្សាយអំពីអរិយធម៌ខ្មែរ
- រាយការណ៍ជូនរាជរដ្ឋាភិបាលជាប្រចាំ នូវលទ្ធផលការងាររបស់ខ្លួន ។

**ប្រការ ៣** : អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសេនាធិការរបស់គណៈកម្មាធិការនេះ អាចប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ គណៈកម្មាធិការនេះ អាចជ្រើសរើសសមាជិកបន្ថែម តាមការចាំបាច់។

**ប្រការ ៤** : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្គត់ផ្គង់ការចំណាយសម្រាប់ការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិសាស្ត្រនេះ ឱ្យបានសម្រេច។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរអប្សរា អាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមានចែងក្នុងប្រការ ៥
- ឯកសារ-កាលប្បវត្តិ